# ការអនុវត្តន៍ល្អ
## ការបង្កើតបណ្ណាល័យ

រោងចក្រ
កាន់តែប្រសើរ
នៅកម្ពុជា

រោងចក្រ ដែលមានកម្មករប្រកបដោយការលើកទឹកចិត្ត និងមានផលិតភាពខ្ពស់ ជារឿយៗមានប្រៀបលើគូប្រកួតប្រជែង ។ ការបង្កើតបណ្ណាល័យសំរាប់ជាអត្ថប្រយោជន៍ដល់កម្មករ គឺជាវិធីសាស្ត្រល្អមួយសំរាប់រោងចក្រ ដើម្បីបង្ហាញការយកចិត្តទុកដាក់ចំពោះកម្មកររបស់ខ្លួន និងកសាងសុច្ឆន្ទៈនៅក្នុងសហគមន៍ ។

### *ការអនុវត្តន៍ល្អក្នុងការបង្កើតបណ្ណាល័យ*

ប្រើប្រាស់ផ្នែកនៃរោងចក្រដែលស្ងប់ស្ងាត់ ឬកន្លែងដែលទុកចោល ( ឬនៅអាគារដាច់ដោយឡែក ) សំរាប់ជាទីតាំងបណ្ណាល័យ ( រូបភាពទី១ ) ។

កត់ត្រាឈ្មោះកម្មករដែលខ្ចីសៀវភៅទៅអាននៅផ្ទះ ( រូបភាពទី២) ។

ផ្តល់គ្រឿងសង្ហារឹមសាមញ្ញៗ ដើម្បីអោយកម្មករអាចអានសៀវភៅនៅក្នុងបណ្ណាល័យ ( រូបភាពទី៣) ។

កម្មករដែលមានចំណាប់អារម្មណ៍អាចប្រើប្រាស់ពេលវេលាទំនេររបស់ពួកគេ ដើម្បីអភិវឌ្ឍ និងទទួលខុសត្រូវលើបណ្ណាល័យ ។ បង្កើតក្រុមកម្មករមួយក្រុម ដើម្បីបង្កើតបណ្ណាល័យ ។

អ្នកគ្រប់គ្រងអាចស្វែងយល់ថា កម្មករដែលមានសេចក្តីប្តេជ្ញាចិត្តចំពោះការសិក្សា ក៏មានផងដែរនូវជំនាញល្អ និងភាពឆ្លាតវាងវៃ ដែលអាចយកមកប្រើប្រាស់នៅកន្លែងដទៃទៀតនៅក្នុងរោងចក្រ ។


រូបភាពទី១


រូបភាពទី២


រូបភាពទី៣

### អត្ថប្រយោជន៍:

- ✓ បង្ហាញទស្សនៈវិជ្ជមានរបស់រោងចក្រទៅកាន់អ្នកទិញ និងសហគមន៍
- ✓ បង្កើនការលក់ទៅអោយបណ្តាអ្នកទិញ ដែលអោយតំលៃទៅលើការទទួលខុសត្រូវផ្នែកសង្គម
- ✓ កសាងសុច្ឆន្ទៈរវាងរោងចក្រ និងកម្មករ
- ✓ កំលាំងពលកម្មដែលរឹតតែមានការអប់រំល្អប្រសើរ
- ✓ អាចអោយអ្នកគ្រប់គ្រងសំគាល់កម្មករ ដែលមានភាពប៉ិនប្រសប់

### តាមរបៀបណា:

- ✓ កំណត់ទីតាំងសមរម្យសំរាប់សាងសង់បណ្ណាល័យ
- ✓ ទាក់ទងអង្គការ Care Cambodia ឬអង្គការក្រៅរដ្ឋាភិបាលនានាដទៃទៀត ដើម្បីសុំជាជំនួយសៀវភៅ ឬជំនួយជាមូលនិធិ

### តំលៃ:

**$**

$ តំលៃទាប
$$ តំលៃមធ្យម
$$$ តំលៃខ្ពស់